# Et j’ai chanté, chanté !

## *ការប្រកួតចម្រៀងហ្វ្រង់កូហ្វូនី*

*វិទ្យាស្ថានបារាំងនៅកម្ពុជា*

## <u>លក្ខខណ្ឌនៃការចូលរួម និងការចុះឈ្មោះ</u>

វិទ្យាស្ថានបារាំងនៅកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា រួមគ្នារៀបចំកម្មវិធីប្រកួតចម្រៀងភាសាបារាំង នៅក្នុងក្របខណ្ឌនៃសប្ដាហ៍ហ្វ្រង់កូហ្វូនី។

**មាត្រា ១ ៖ លក្ខខណ្ឌចូលរួម**

**បេក្ខជន**ដែលមានអាយុពី**១០ឆ្នាំ ដល់៣០ឆ្នាំ** និងមានទីលំនៅក្នុងប្រទេសកម្ពុជាអាចដាក់ពាក្យចូលរួមក្នុងការប្រកួតប្រជែងនេះបាន លើកលែងអ្នកនិយាយភាសាបារាំងពីកំណើត។

បេក្ខជនអាចច្រៀងតែម្នាក់ឯងក៏បាន ឬជាក្រុមក៏បាន។

បេក្ខជន ឬក្រុមនីមួយៗត្រូវថតសំឡេងចម្រៀងដែលខ្លួនច្រៀង**មួយបទ** តាមជម្រើសរបស់ខ្លួន។ បទចម្រៀងនេះ ត្រូវតែជាភាសាបារាំងពីដើមដល់ចប់។ ដើម្បីជួយផ្ដល់ជាគំនិតលើការជ្រើសរើសបទចម្រៀង បេក្ខជនអាចទៅមើលនៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយលក្ខខណ្ឌនៃការចូលរួមនេះ។

បេក្ខជនត្រូវផ្ញើសំឡេងច្រៀងដែលខ្លួន ឬក្រុមខ្លួនបានថតនេះក្រោម<u>**ទម្រង់mp3**</u> ដោយត្រូវប្រុងប្រយ័ត្នចំពោះគុណភាពនៃការថតសំឡេង ពីព្រោះថា ការជ្រើសរើសជំណាក់កាលទីមួយផ្អែកលើសំឡេងដែលថតនេះ។

ឈ្មោះរបស់ឯកសារសំឡេងនេះ ត្រូវមានដាក់ឈ្មោះបេក្ខជន (ឬឈ្មោះក្រុម) និងចំណងជើងបទចម្រៀង (ឧទាហរណ៍៖ នាម.គោត្តនាម_ចំណងជើងបទចម្រៀង)។ បេក្ខជនត្រូវផ្ញើសំឡេងដែលបានថតនេះ ដោយភ្ជាប់ទម្រង់បែបបទចុះឈ្មោះដែលមានភ្ជាប់ជាមួយនេះ។

ដើម្បីចៀសវាងរាល់ការលំបាកក្នុងការផ្ញើសំឡេងចម្រៀងថតក្រោមទម្រង់ជាmp3 ដែលមានទំហំធំមកកាន់ពួកយើង បេក្ខជនអាចប្រើប្រព័ន្ធចែកចាយឯកសារអនឡាញ (dropbox, Wetransfer, Smash.fr…)បាន។ សូមទាក់ទងមកយើងខ្ញុំ ក្នុងករណីដែលមានបញ្ហា។

## មាត្រា ២ ៖ ការជ្រើសរើសបេក្ខជន

បេក្ខជនត្រូវផ្ញើសំឡេងចម្រៀងដែលបានថត និងទម្រង់បែបបទចុះឈ្មោះមានចុះហត្ថលេខា ទៅកាន់លោកស្រី Amélie Gauch (amelie.gauch@institutfrancais-cambodge.com) យ៉ាងយូរបំផុតត្រឹមថ្ងៃទី**៩ ខែមីនា ឆ្នាំ២០២៣**។

បេក្ខជនដែលត្រូវបានជ្រើសរើសដោយវិទ្យាស្ថានបារាំង នឹងត្រូវបានអញ្ជើញចូលរួមប្រកួតវគ្គផ្តាច់ព្រ័ត្រ នៅថ្ងៃ**ទី២៣ ខែមីនា ឆ្នាំ២០២៣** នៅចំពោះមុខសាធារណជន នៅវិទ្យាស្ថានបារាំងនៅកម្ពុជា។

នៅថ្ងៃទី២៣ ខែមីនា បេក្ខជនដែលចូលរួមវគ្គផ្តាច់ព្រ័ត្រត្រូវច្រៀងបទចម្រៀង ដែលខ្លួនបានផ្ញើមកពេលចុះឈ្មោះ។ បេក្ខជនដែលទទួលបានជ័យលាភីនៅវគ្គផ្តាច់ព្រ័ត្រ នឹងទទួលបានរង្វាន់ទៅតាមចំណាត់ថ្នាក់។

## មាត្រា ៣ ៖ សិទ្ធិក្នុងការផ្សព្វផ្សាយរូបភាព

នៅក្នុងការប្រកួតនេះ យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការថតរូបភាព និងវីដេអូរបស់បេក្ខជនទាំងអស់ ដែលនឹងអាចត្រូវបានយកទៅផ្សព្វផ្សាយនៅលើបណ្តាញសង្គម និងលើគេហទំព័ររបស់វិទ្យាស្ថានបារាំងនៅកម្ពុជា និងដៃគូសហការរបស់ខ្លួន។

ការចុះហត្ថលេខារបស់បេក្ខជនទាំងអស់នៅលើទម្រង់បែបបទចុះឈ្មោះ បញ្ជាក់ថាបេក្ខជនយល់ព្រមចំពោះលក្ខខណ្ឌខាងលើនេះ។

## មាត្រា ៤ ៖ កាលបរិច្ឆេទសំខាន់ៗ

- រហូតដល់ថ្ងៃទី៩ ខែមីនា ៖ ទទួលចុះឈ្មោះបេក្ខជន
- ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ៖ ប្រកាសឈ្មោះបេក្ខជនដែលមានសិទ្ធិចូលរួមប្រកួតវគ្គផ្តាច់ព្រ័ត្រ
- ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ៖ ការហាត់សម និងការប្រកួតផ្តាច់ព្រ័ត្រ

## មាត្រា ៥ ៖ លក្ខខណ្ឌនៃការជ្រើសរើស

លក្ខខណ្ឌនៃការជ្រើសរើសក្នុងដំណាក់កាលទី១ រួមមាន៖

- គុណភាពសម្លេង
- ការបកស្រាយបទចម្រៀង
- គំនិតច្នៃប្រឌិតក្នុងការជ្រើសរើសបទចម្រៀង ឬក្នុងការបកស្រាយបទចម្រៀង
- គុណភាពក្នុងការបញ្ចេញសំឡេងជាភាសាបារាំង

ការរៀបចំតុបតែងខ្លួន ក៏ជាកត្តាមួយក្នុងការជ្រើសរើសបេក្ខជននៅវគ្គផ្តាច់ព្រ័ត្រផងដែរ។

**មាត្រា ៦ ៖ គណៈកម្មការ**

ការសម្រេចចិត្តរបស់គណៈកម្មការនៅវគ្គផ្តាច់ព្រ័ត្រ គឺធ្វើឡើងដោយឆន្ទានុសិទ្ធិ និងបិទផ្លូវតវ៉ា។

**មាត្រា ៧ ៖ វគ្គផ្តាច់ព្រ័ត្រនៅរាជធានីភ្នំពេញ**

ចំណាយលើការធ្វើដំណើរមកកាន់រាជធានីភ្នំពេញ ការស្នាក់នៅ និងអាហារ ជាបន្ទុករបស់បេក្ខជនផ្ទាល់។ បេក្ខជនដែលត្រូវបានជ្រើសរើសឱ្យចូលរួមវគ្គផ្តាច់ព្រ័ត្រ ត្រូវតែចូលរួមក្នុងការហាត់សមដែលនឹងប្រព្រឹត្តទៅនៅវិទ្យាស្ថានបារាំងនៅកម្ពុជានាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ជាកំហិត។ បេក្ខជនដែលជាអនីតិជន ត្រូវតែមានអាណាព្យាបាលនៅជាមួយតាំងពីពេលចាប់ផ្តើមរហូតដល់ចប់កម្មវិធី។

**ឧបសម្ព័ន្ធ៖ ជំនួយស្មារតីក្នុងការជ្រើសរើសបទចម្រៀង**

បេក្ខជនអាចជ្រើសរើសបទចម្រៀងចេញពីក្នុងបញ្ជីខាងក្រោមបាន៖

១/ **បទចម្រៀងបារាំងថ្មីៗ** ៖ Angèle, Pomme, Clara Luciani, Juliette Armanet, Yseult, Suzane, Lous and the Yakuza, Chilla, Stromae, Camelia Jordana, Slimane, Diam's, Vitaa, BB Brunes -ល-

២/ បទចម្រៀងបារាំងពិរោះៗល្បីៗ ៖ Benjamin Biolay, M (Matthieu Chedid), Téléphone, Cœur de Pirate, Céline Dion (en français), Benabar, Patrick Bruel, Louis Attaque, Raphaël, Vincent Delerm, Tryo, Kali, Kyo, Vanessa Paradis, France Gall, Françoise Hardy, Véronique Sanson, Michel Sardou, Francis Cabrel, Jacques Higelin, Boby Lapointe…

៣/ **បទចម្រៀងមរតកបារាំង** ៖ Joe Dassin, Barbara, Charles Aznavour, Serge Reggiani, Léo Ferré, Georges Brassens, Jean Ferrat, Claude Nougaro, Boris Vian, Juliette Gréco, Yves Montand, Charles Trénet -ល- **ដែលត្រូវបានច្រៀងឡើងវិញតាមបែបសម័យ**

៤/ **ការតាក់តែងបទថ្មី៖** យើងខ្ញុំលើកទឹកចិត្តបេក្ខជនឲ្យបង្កើតបទចម្រៀងថ្មីដោយខ្លួនឯង!

តារាចម្រៀងដូចដែលបានរាយនាមខាងលើ បានច្រៀងចម្រៀងជាច្រើនដែលលោកអ្នកអាចយកមកច្រៀងក្នុងការប្រកួតនេះបាន។ ដើម្បីទទួលបានគំនិតច្រើនជាងនេះក្នុងការជ្រើសរើសស្ទីលបទភ្លេងដែលលោកអ្នកស្រឡាញ់ចូលចិត្ត សូមកុំស្ទាក់ស្ទើរក្នុងការស្វែងរកមើលកម្រងបទចម្រៀងនៅលើអ៊ីនធើណេត (Spotify, Youtube, Deezer -ល-) ។

ការច្នៃប្រឌិតថ្មី ក៏នឹងធ្វើឲ្យបេក្ខជន ទទួលបានពិន្ទុដែរ ហេតុនេះហើយ សូមកុំស្ទាក់ស្ទើរក្នុងការស្វែងរកបទចម្រៀងរបស់តារាចម្រៀងមួយរូប ដែលនឹងអាចធ្វើឲ្យគណៈកម្មការភ្ញាក់ផ្អើល!